# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### កិច្ចព្រមព្រៀង
### រវាងតំណាងបុគ្គលិកសណ្ឋាគារ សុខាអង្គរ
### និងនិយោជកនៃសណ្ឋាគារ សុខាអង្គរ

អនុស្សរណៈនៃការយោគយល់នេះត្រូវបានធ្វើឡើងនៅថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០២០ រវាងប្រធានផ្នែកនៃសណ្ឋាគារ សុខាអង្គរ (ពីនេះតទៅហៅថា "តំណាងបុគ្គលិក") និងតំណាងសណ្ឋាគារ សុខា អង្គរ (ពីនេះតទៅហៅថា "និយោជក")។

ដោយសារតែការផ្ទុះឡើងនូវជំងឺកូវីត ១៩ ដែលកំពុងតែឆ្លងរាលដាលយ៉ាងខ្លាំង នៅទូទាំងពិភពលោកនាពេលនេះ បានធ្វើឲ្យអាជីវកម្មសណ្ឋាគារ សុខាអង្គរជួបប្រទះនូវការលំបាកផ្នែកហិរញ្ញវត្ថុយ៉ាងធ្ងន់ធ្ងរបំផុត។ ហេតុនេះ ដើម្បីសម្រាលនូវបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរនៅចំពោះមុខនេះ និយោជក និងតំណាងបុគ្គលិក បានចរចារ និងព្រមព្រាងគ្នាដាក់ឲ្យបុគ្គលិកមួយភាគធំឈប់សម្រាកពីការងារដោយឥតប្រាក់ឈ្នួល រយៈពេលពីរ (២) ខែ គិតចាប់ពីថ្ងៃទី ០១ ខែមេសា ដល់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០។

ភាគីទាំងពីរបានព្រមព្រៀងគ្នា លើលក្ខខណ្ឌដូចខាងក្រោម៖

- និយោជិតដែលត្រូវបានដាក់ឲ្យឈប់សម្រាកពីការងាររយៈពេលពីរ (២) ខែ នឹងមិនទទួលបានប្រាក់ឈ្នួល និងប្រាក់ធានានុគ្រោះទេ នៅក្នុងអំឡុងពេលនៃការឈប់សម្រាកនេះ។
- អតីតភាពការងាររបស់និយោជិតដែលដាក់ឲ្យឈប់សម្រាកដោយឥតប្រាក់ឈ្នួល នឹងមិនត្រូវបានប៉ះពាល់ឡើយ។
- ដើម្បីសម្រួលដល់ជីវភាពនិយោជិត នៅក្នុងអំឡុងពេលនៃការឈប់សម្រាកពីការងារដោយឥតប្រាក់ឈ្នួលរយៈពេលពីរ (២) ខែនេះ និយោជកបានសម្រេចដកប្រាក់មូលនិធិជំនួយបន្ទាន់ស្មើរតែ ១០០% មកបែងចែកជូននិយោជិតសណ្ឋាគារទាំងអស់ ដែលមានចំនួនសរុប ២៧៣ នាក់ ដែលជាមធ្យមនិយោជិតម្នាក់ៗទទួលបានប្រាក់មូលនិធិជំនួយបន្ទាន់នេះចំនួន ២៨២ដុល្លារអាមេរិក។

ចំពោះនិយោជិតដែលត្រូវរក្សាទុកក្នុងចំនួនអប្បបរមា ទៅតាមតម្រូវការជាក់ស្តែងនៃផ្នែកនីមួយៗសម្រាប់ធ្វើការពេញម៉ោង (៤សប្តាហ៍) ក្នុងមួយខែ៖

- និយោជិតធម្មតានឹងទទួលបានប្រាក់ឈ្នួល ១០០%។
- និយោជិតថ្នាក់ប្រធាន/អនុប្រធានផ្នែក នឹងទទួលបានប្រាក់ឈ្នួល ៥០% នៃប្រាក់ខែគោល ព្រមទាំងប្រាក់ ឧបត្ថម្ភអាហារចំនួន ៥.០០ដុល្លារអាមេរិក សម្រាប់ ១ថ្ងៃធ្វើការ។

- និយោជិតថ្នាក់ប្រធាន/អនុប្រធានផ្នែក ដែលតម្រូវឲ្យធ្វើការបួន (៤) ថ្ងៃក្នុងមួយខែ នឹងទទួលបានប្រាក់ឈ្នួល ៥០% នៃប្រាក់ខែគោល ដោយគណនាទៅតាមចំនួនថ្ងៃធ្វើការជាក់ស្តែងរបស់និយោជិតនីមួយៗ ព្រមទាំងប្រាក់ឧបត្ថម្ភអាហារចំនួន ៥.០០ដុល្លារអាមេរិក សម្រាប់ ១ថ្ងៃធ្វើការ។
- និយោជិតថ្នាក់គ្រប់គ្រងទូទៅ និងគ្រប់គ្រងប្រតិបត្តិការត្រូវធ្វើការពេញម៉ោង ដោយមិនទទួលបានប្រាក់បៀវត្ស។

សូមបញ្ជាក់ថា ចំណុចដូចដែលបានរៀបរាប់ខាងលើនេះ គឺសម្រាប់ការអនុវត្តរយៈពេលពីរ (២) ខែ គិតចាប់ពីថ្ងៃទី០១ ខែមេសា ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០។ ក្រុមហ៊ុននឹងធ្វើការជូនដំណឹងជាថ្មី ប្រសិនបើស្ថានការណ៍មានការប្រែប្រួល ហើយគូភាគីនឹងពិនិត្យមើលអនុស្សរណៈនៃការយោគយល់នេះពីខាងក្រោមនេះៈ

**ហត្ថលេខាភាគីតំណាងនិយោជក**

សាខាក្រុមហ៊ុន សុខា អូតែល
សណ្ឋាគារសុខាអង្គរ
SOKHA ANGKOR HOTEL
BRANCH OF SOKHA HOTEL CO.,LTD.

**ហត្ថលេខាភាគីតំណាងនិយោជិត**

សុខ សារ៉ាយុទ្ធ ______

អ៊ុក សុធា ______

ភ៉ន់ ចំណាន ______

សាយ មុន្នី ______

ប៊ិន សាលីន ______

កាន់ គង់ហេង ______

អ៊ូ ស៊ុក ______